ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

-សាលក្រមព្រហ្មទណ្ឌ
លេខ: ៥៣៥ "ផ" ក្រ.ជ ✓
ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៩
-សំណុំរឿងព្រហ្មទណ្ឌ
លេខ: ៤១៣០
ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៨
-ស៊ើបសួរលេខ: ២៤១២
ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៨
-ជំនុំជម្រះលេខ: ១៣៣៦
ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៩

# តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈនៅសាលាដំបូងរាជធានីភ្នំពេញនាថ្ងៃទី១៧ខែមិថុនា ឆ្នាំ២០១៩ ដែលមានសមាសភាពដូចតទៅ៖

### ក្រុមប្រឹក្សាជំនុំជម្រះ

- លោក [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
- លោក [redacted] ចៅក្រមប្រឹក្សា
- លោក [redacted] ចៅក្រមប្រឹក្សា

### តំណាងអយ្យការ

- លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

### ក្រឡាបញ្ជីសវនាការ

- លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ៤១៣០ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៨ ដែលមានជនជាប់ចោទ៖

១/ឈ្មោះ [redacted] ហេង ភេទប្រុស អាយុ ១៩ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ កាន់សាសនាព្រះពុទ្ធ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើត[redacted] ក្រុងភ្នំពេញ ទីលំនៅបច្ចុប្បន្នភូមិក្រាលគោ ឃុំសំបួរមាស ស្រុកមុខកំពូល ខេត្តកណ្តាល នៅលីវ ឪពុកឈ្មោះ [redacted] ហួង "រ" ម្តាយឈ្មោះ [redacted] ចាន់ពៅ "រ" ទោសពីមុនគ្មាន ជានីតិជន ។ ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ: ៥៥៣៨ ង.១ ដ.ឃ.ដ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៨។

២./ឈ្មោះ [redacted] សីហា ភេទប្រុស អាយុ ២៥ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ កាន់សាសនាព្រះពុទ្ធ មុខរបររត់រ៉ឺម៉ក ទីកន្លែងកំណើត[redacted] ក្រុងភ្នំពេញ ទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះលេខ០៤៦ ភូមិឆេកូ គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ម៉ៅ "រ" ម្តាយឈ្មោះ [redacted] សុខហេង "រ" ប្រពន្ធឈ្មោះ [redacted] វ៉ាមី "រ" គ្មានកូន ទោសពីមុនគ្មាន ជានីតិជន។ ដីកាបង្គាប់ឲ្យឃាត់ខ្លួនលេខ:៥៥៣៩ "ង.១" ដ.ឃ.ដ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៨។

ដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ: លួចមានស្ថានទម្ងន់ទោសដោយការប្រព្រឹត្តអំពើហឹង្សា ប្រព្រឹត្តនៅចំណុចផ្លូវព្រះនរោត្តម កែងផ្លូវលេខ១៣៦ ភូមិទី១០ សង្កាត់ផ្សារថ្មី២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៨ បទល្មើសដែលមានបញ្ជូត្តិឱ្យផ្តន្ទាទោសតាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

-លោក [redacted] ជាមេធាវីការពារសិទ្ធិ[redacted]អោយជនជាប់ចោទឈ្មោះ [redacted] ហេង។

-លោក [redacted] ជាមេធាវីការពារសិទ្ធិអោយជនជាប់ចោទឈ្មោះ [redacted] សីហា។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] នីតា ភេទស្រី អាយុ២៣ឆ្នាំ ជាតិខ្មែរ មុខរបរបុគ្គលិកហាងម៉ាស្សា ទីកន្លែងកំណើតភូមិព្រៃល្វា សង្កាត់ចោមចៅ ខណ្ឌដង្កោ ក្រុងភ្នំពេញ ទីលំនៅសព្វថ្ងៃផ្លូវលំ ភូមិព្រៃល្វា សង្កាត់ចោមចៅទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] សុង "រ" ម្តាយឈ្មោះ [redacted] ពិសាធ "រ"។

## អង្គហេតុនៃការចោទប្រកាន់មានដូចតទៅ ÷

កាលពីថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៨ វេលាម៉ោង ២០ និង៤៥នាទី នៅចំណុចផ្លូវព្រះនរោត្តម កែងផ្លូវលេខ១៣៦ ភូមិទី១០ សង្កាត់ផ្សារថ្មី២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ មានករណីលួចមានស្ថានទម្ងន់ទោសបានកើតឡើង ខណៈពេលដែលជនរងគ្រោះឈ្មោះ [redacted] នីតា ភេទស្រី អាយុ២៣ឆ្នាំ បានជិះម៉ូតូតែម្នាក់ឯងដល់ចំណុចខាងលើនោះ ស្រាប់តែមានជនត្រូវចោទ០៣នាក់ បានជិះម៉ូតូមួយគ្រឿងតាមពីក្រោយជនរងគ្រោះ រួចធ្វើសកម្មភាពឆក់កាបូបស្ពាយពណ៌ទឹកប្រាក់របស់ជនរងគ្រោះដែលព្យួរនៅចន្លោះភ្លៅបណ្តាលឱ្យដួលម៉ូតូទាំងពីរគ្រឿង ភ្លាមនោះប្រជាពលរដ្ឋ និងកម្លាំងល្បាតបានចុះមកអន្តរាគមន៍ឃាត់ខ្លួនបានជនត្រូវចោទម្នាក់ឈ្មោះ [redacted] ហេង ភេទប្រុស អាយុ១៩ឆ្នាំ ។ លុះមកដល់ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៨ សមត្ថកិច្ចបានស្រាវជ្រាវ និងឃាត់ខ្លួនបានជនត្រូវចោទម្នាក់ទៀតឈ្មោះ [redacted] សីហា ភេទប្រុស អាយុ២៥ឆ្នាំ បញ្ជូនទៅអធិការដ្ឋាននគរបាលខណ្ឌដូនពេញ ដើម្បីចាត់ការតាមនីតិវិធី ចំណែកជនត្រូវចោទឈ្មោះ **វិទ្ធ** ភេទប្រុស អាយុ ប្រហែល ២០ឆ្នាំ បានរត់គេចខ្លួនបាត់។

-បានឃើញរបាយការណ៍សំយោគលេខ: ០៧៧/២០១៨ រ.ប.ក ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៨ របស់អធិការនគរបាលខណ្ឌដូនពេញ។

-បានឃើញដីកាសន្និដ្ឋានស្តាពរលេខ ១២៦៦ អយរ ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៩ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ១៦៦៨ ដ.ដ ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

**ឆាពេលសវនាការ**

-ជនជាប់ចោទឈ្មោះ [redacted] ហេង បានឆ្លើយថា៖ ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៨ វេលាម៉ោង ០៩នាទីយប់ ខ្ញុនបានជិះម៉ូតូមួយគ្រឿងម៉ាក BEET ពណ៌ក្រហម មានស្លាកលេខតែខ្ញុនមិនចាំ ដឹកឈ្មោះ **រិទ្ធ** និងឈ្មោះ [redacted] **សីហា** ដល់ចំណុចកើតហេតុក៏បានជ្រុលចង្កូតទៅបុកជាមួយម៉ូតូជនរងគ្រោះម៉ាកនិចមួយគ្រឿង ពណ៌ស និងមួយគ្រឿងទៀត ម៉ាកធូដេ ពណ៌ផ្កាឈូក បើកបរដោយជនរងគ្រោះជានារីបើកម្នាក់ឯង បណ្តាលឲ្យខ្ញុនសន្លប់បាត់ស្មារតី ក្រោយពេលដឹងខ្ញុនវិញគឺខ្ញុនត្រូវបានសមត្ថកិច្ចដឹកយកទៅប៉ុស្តិ៍ប៉ូលីសដើម្បីសួរចម្លើយ។ នៅថ្ងៃកើតហេតុខ្ញុនមិនបានធ្វើសកម្មភាពរត់ការបូបរបស់ជនរងគ្រោះនោះទេ ហើយបានជាជនរងគ្រោះមានរបួសដោយសាររតែខ្ញុនបានបើកម៉ូតូទៅបុកព្រោះនៅថ្ងៃកើតហេតុនៅតាមផ្លូវបត់ទៅវត្តភ្នំស្ងាត់ ខ្ញុនក៏បានបន្តែមល្បឿនទើបធ្វើឲ្យមានរឿងហេតុនេះកើតឡើង ចំពោះចម្លើយរបស់ដើមបណ្តឹងឈ្មោះ [redacted] **នីតា** ដែលក្រឡាបញ្ជីបានអានឲ្យខ្ញុនស្តាប់ខ្ញុនសុំបដិសេធចោលទាំងស្រុង ព្រោះខ្ញុនមិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ។ ឈ្មោះ **រិទ្ធ** ខ្ញុនស្គាល់ឈ្មោះហើយជាអ្នកភូមិជាមួយគ្នា តែមិនដែលដើរលេងជាមួយគ្នាទេ ទើបតែថ្ងៃកើតហេតុឈ្មោះ **រិទ្ធ** វាបានខលហៅឲ្យខ្ញុនមកជួយដឹកវាទៅយកម៉ូតូពីបងវានៅហាងត្បាល់ខ្មែរ រឿងផ្សេងពីនេះខ្ញុនពុំដឹងទេ។

សូមលោកតុលាការមេត្តាលើកលែងចោទប្រកាន់ ព្រោះខ្ញុនពុំបានប្រព្រឹត្តដូចការចោទប្រកាន់នេះទេ។

-ជនជាប់ចោទឈ្មោះ [redacted] **សីហា** បានឆ្លើយថា: នៅចំពោះមុខសមត្ថកិច្ចកាលពីថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ២០១៨ ខ្ញុំទៅលើកឥវ៉ាន់ឲ្យគេនៅរង្វង់មូលផ្សារដើមគរជាមួយក្មួយឈ្មោះ [redacted] **ហេង** ដោយជិះម៉ូតូម៉ាក BET ហុងដា ឆ្នាំ២០១៧ ពណ៌ក្រហម មិនចាំស្លាកលេខជារបស់ឈ្មោះ [redacted] **ហេង** បន្ទាប់ពីលើឥវ៉ាន់រួចឈ្មោះ [redacted] **ហេង** បានឌុបខ្ញុំទៅយកឈ្មោះ **រិទ្ធ** ភេទប្រុស អាយុ ១៩ឆ្នាំ អាសយដ្ឋានមិនស្គាល់នៅការ៉ាស់សាំងតេលាជ្រោយចង្វារពេលទៅដល់យកឈ្មោះ **រិទ្ធ** នៅពេលយប់មិនចាំម៉ោងដោយឈ្មោះ **រិទ្ធ** ឲ្យជួយជូនទៅយកម៉ូតូបងវានៅហាងត្បាល់ខ្មែរម្តុំសាលាព្រះស៊ីសុវត្ថិពេលទៅដល់ហាងត្បាល់ខ្មែរ បងរបស់ឈ្មោះ **រិទ្ធ** ក៏រវល់ហើយពួកខ្ញុំក៏ជិះម៉ូតូត្រឡប់ទៅផ្ទះវិញដោយជិះតាមផ្លូវព្រះមុនីវង្សបត់ទៅតាមផ្លូវផ្សារថ្មីក៏ឃើញម៉ូតូជនរងគ្រោះ ម៉ាកនិច ពណ៌ស ជិះម្នាក់ឯង និងម៉ូតូ ធូដេ នៅពេលនោះឈ្មោះ រិទ្ធ ក៏បានលើកម៉ូតូរបស់ឈ្មោះ [redacted] ហេង ហៅខ្ញុំជិះទៅជាមួយដើម្បីគេចព្រោះខ្លាចប្រជាជនវៃពួកខ្ញុំ ចំពោះឈ្មោះ [redacted] ផេង ដេកដួលនៅកន្លែងកើតហេតុ ខ្ញុំមិនបានធ្វើសកម្មភាពរត់ការបូបជនរងគ្រោះនោះទេ។ ពីមុនមកខ្ញុំមិនដែលធ្វើសកម្មភាពធ្ងន់ទេ។

សំណូមពរ: សុំឲ្យតុលាការជួយរកយុត្តិធម៌ដល់ខ្ញុំផង ព្រោះខ្ញុំមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ សុំលើកលែងចោទប្រកាន់ដល់ខ្ញុនផង។

-តាមអំណានចំលើយដើមបណ្តឹងរដ្ឋប្បវេណី [redacted] **នីតា** បានឆ្លើយថានៅចៅក្រមស៊ើបសួរថា: ហេតុការណ៍កើតនៅ កាលពីថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៨ ម៉ោងប្រហែល០៨ និង៣០នាទីយប់ ខ្ញុំជិះម៉ូតូម៉ាកធូដេ ពណ៌ផ្កាឈូក មិនចាំស្លាកលេខ ជាម៉ូតូរបស់ខ្ញុំជិះចេញពីធ្វើការនៅម្តុំប៉ុលឌីញ ទៅតាមផ្លូវព្រះនរោត្តមមិនដឹងដល់ចំណុចណាទេ ស្រាប់តែមានចោរឆក់កាបូបខ្ញុំដួលម៉ូតូសន្លប់តែម្តង មិនដឹងរឿងហេតុការណ៍អ្វីទៀតទេ ចោរឆក់កាបូបខ្ញុំមិនដឹងមានគ្នាប៉ុន្មាននាក់ទេ មិនស្គាល់មុខ និងមិនដឹងចោរឆក់នោះ ជិះម៉ូតូម៉ាកអ្វីដែរ។ ពេលខ្ញុំដួលម៉ូតូ បានទៅដេក

ពេទ្យកាល់ម៉ែត្រព្យាបាលរយៈពេល ៥ថ្ងៃ ខ្ញុំត្រូវរបួសបាក់ឆ្អឹងដងកាំបិតខាងស្តាំ ដាច់មុខផ្នែកខាងស្តាំ ដាច់ចិញ្ចើមខាងឆ្វេង ដេរចំនួន ០៨ថ្នេរ និងស្រាំឆ្អឹងក្នុងត្រចៀកខាងស្តាំ ដោយស្តាប់មិនលឺទេសព្វថ្ងៃនេះ ផ្នែព្យាបាលខ្ញុំមិនដឹងអស់ប៉ុន្មានទេ ចាំខ្ញុំដាក់ភស្តុតាងឯកសារផ្នែពេទ្យតាមក្រោយ ។ ករណីនេះមិនមែនជាករណីគ្រោះថ្នាក់ចរាចរណ៍ទេ គឺករណីធក់កាបូប។

ខ្ញុំសុំសំណូមពរដល់តុលាការ ខ្ញុំសុំទាមទារសំណងជម្ងឺផ្នែព្យាបាល ខាតបង់ពេលវេលា ជាទឹកប្រាក់សរុបចំនួន ១២,០០០,០០០ (ដប់ពីរលាន)រៀល ចំពោះជនត្រូវចោទសុំឲ្យតុលាការផ្តន្ទាទោសតាមច្បាប់។

-តាមអំណានចំលើយសាក្សីឈ្មោះ [redacted] ដានី នៅអធិការនគរបាលខណ្ឌដូនពេញថា: កាលពីថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៨ វេលាម៉ោង២០:៤៥នាទី នាងខ្ញុំបានជិះម៉ូតូពីកន្លែងធ្វើការ នៅក្នុងសង្កាត់ទន្លេបាសាក់ មកផ្ទះតាមបណ្តោយផ្លូវព្រះនរោត្តម្ភោះមកទិសខាងជើងជាមួយនឹងមិត្តភ័ក្ត្រម្នាក់ទៀតឈ្មោះ នីតា ភេទស្រី អាយុ២៣ឆ្នាំ ធ្វើការជាមួយគ្នា (ជិះម៉ូតូមួយម្នាក់) លុះជិះមកដល់ចំណុចផ្លូវព្រះនរោត្តមកែងផ្លូវ១៣៦ ស្រាប់តែមានម៉ូតូមួយគ្រឿងផ្សេងទៀតជិះគ្នាបីនាក់ ប្រុសទាំងអស់បានមកបុកម៉ូតូនាងខ្ញុំកំពុងជិះទន្ទឹមគ្នាបានដួលទាំងអស់គ្នាតែម្តង ហើយអ្នកបុកនោះបានស្ទុះលើកម៉ូតូរបស់ខ្លួនជិះរត់គេចខ្លួនតាមបណ្តោយផ្លូវ១៣៦ ទៅកើតដោយបន្សល់ទុកមិត្តភ័ក្ត្រម្នាក់នៅកន្លែងកើតហេតុ ហើយត្រូវបានប្រជាពលរដ្ឋមកចោមរោមមើលពាសពេញផ្លូវ ហើយពេលកើតហេតុគឺនៅវេលាម៉ោង២១:00នាទី។

-តាមអំណានរបាយការណ៍សំយោគលេខ ០៧៧/២០១៨ របក ចុះថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ២០១៨ របស់អធិការនគរបាលខណ្ឌដូនពេញ។

## <u>សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ</u>

ឆ្លងតាមសវនាការជនជាប់ចោទបានឆ្លើយបដិសេធខ្លួនពុំបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ គឺជារឿងគ្រោះថ្នាក់ចរាចរណ៍ទេ នេះគ្រាន់តែជាចំលើយដោះសារប៉ុណ្ណោះ ព្រោះគ្មានភស្តុតាងណាមួយដែលអាចអោយតុលាការជឿជាក់បានឡើយ ព្រោះដើមបណ្តឹងបានឆ្លើយបញ្ជាក់យ៉ាងច្បាស់ថា ជនជាប់ចោទបានធក់កាបូបរបស់ខ្លួនបណ្តាលអោយដួសម៉ូតូ បណ្តាលអោយដើមបណ្តឹងត្រូវរបួសជាទម្ងន់ និងជនជាប់ចោទសន្តប់នៅកន្លែងកើតហេតុ គឺមានធាតុផ្សំបទល្មើសគ្រប់គ្រាន់សម្រាប់ដាក់បន្ទុកលើជនជាប់ចោទ។ ដូចនេះតំណាងអយ្យការតំកល់ការចោទប្រកាន់ទុកនៅដដែល សូមលោកក្រុមប្រឹក្សាសំរេចទៅតាមច្បាប់។

## <u>សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ</u>

-លោក [redacted] ជាមេធាវីការពារឲ្យជនជាប់ចោទឈ្មោះ [redacted] សីហា បានធ្វើសេចក្តីសន្និដ្ឋានថា: ឆ្លងតាមសវនាការ កូនក្តីខ្លួនបានឆ្លើយបដិសេធតាំងពីដំណាក់កាលនគរបាល និងរហូតដល់ពេលសវនាការ គឺកូនក្តីខ្លួនពុំបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ គឺកូនក្តីខ្លួនពុំបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ គឺជារឿងគ្រោះថ្នាក់ចរាចរណ៍ ពេលសមត្ថកិច្ចហៅមកបំភ្លឺរឿងអ្នកគ្រោះថ្នាក់ចរាចរណ៍ គឺកូនក្តីខ្លួនមកបំភ្លឺតាមការកោះហៅដោយពុំមានចេតនាគេចវេសឡើយ។ ដូចនេះកូនក្តីខ្លួនមានភាពស្មោះត្រង់ បើសិនជាកូនក្តីប្រព្រឹត្តមែននោះច្បាស់ជាកូនក្តីខ្ញុំ

រត់គេចខ្លួនបាត់ហើយ ដោយពុំចាំបាច់ចូលមកបំភ្លឺអោយសមត្ថកិច្ចឃាត់ខ្លួនបានឡើយ។ ដូចនេះសុំអោយកូនក្តីខ្ញុំរួចផុតពីបទចោទ។ បើសិនតុលាការរកឃើញថាកូនក្តីខ្ញុំប្រព្រឹត្ត សូមលោកតុលាការមេត្តាជួយបន្ធូបន្ថយទោស។

-លោក [redacted] ជាមេធាវីការពារអោយជនជាប់ចោទឈ្មោះ [redacted] **ហេង** បានធ្វើសេចក្តីសន្និដ្ឋានថា: ឆ្លងតាមសវនាការកូនក្តីខ្លួនបានឆ្លើយតាំងពីនៅសមត្ថកិច្ចនគរបាលរហូតដល់ពេលសវនាការថា: ខ្លួនពុំបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ គឺជារឿងគ្រោះថ្នាក់ចរាចរណ៍ដែលកូនក្តីខ្លួន និងដើមបណ្តឹងបណ្តាលឱ្យរបួសទាំងសងខាង គឺកូនខ្លួនឈ្មោះ [redacted] **ហេង** បានសន្លប់ហើយយកទៅព្យាបាលនៅមន្ទីរពេទ្យ ហើយសាក្សីឈ្មោះ [redacted] **ដានី** ភេទស្រី កើតឆ្នាំ១៩៩២ បានឆ្លើយបញ្ជាក់ថា: ម៉ូតូកូនក្តីខ្ញុំ និងដើមបណ្តឹងជិះទង្គិចគ្នា ហើយបុកគ្នាបណ្តាលអោយដួល ហើយមានប្រជាពលរដ្ឋចោមរោមមើល។ ដូចនេះជារឿងគ្រោះថ្នាក់ចរាចរណ៍ សូមលោកចៅក្រមលើកលែងចោទប្រកាន់កូនក្តីខ្លួនដោយអនុគ្រោះ។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចំលើយដើមបណ្តឹង

-ក្រោយពីបានស្តាប់អំណានចំលើយសាក្សី

-ក្រោយពីបានស្តាប់អំណានឯកសារផ្សេងៗ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យ និងពិចារណាលើសំណុំរឿងចប់សព្វគ្រប់រួមហើយ។

## សំអាងហេតុ

-តាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ១៦៦៨ "ង១" ដ.ដ ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ ២០១៩ របស់ចៅក្រមស៊ើបសួរបានបញ្ជូនជនជាប់ចោទឈ្មោះ [redacted] **ហេង** ភេទប្រុស អាយុ១៩ឆ្នាំ និងឈ្មោះ [redacted] **សីហា** ទៅជំនុំជម្រះ **ពីបទ: លួចមានស្ថានទម្ងន់ទោស ដោយការប្រព្រឹត្តអំពើហិង្សា** តាមមាត្រា ៣៥៣, ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] **ហេង** និងឈ្មោះ [redacted] **សីហា** បានឆ្លើយបដិសេធប្រហាក់ប្រហែលគ្នាថា: នៅថ្ងៃកើតហេតុថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៨ វេលាម៉ោងប្រហែល៩យប់ ខ្លួនបានជិះម៉ូតូដឹកឈ្មោះ **វិទ្ធ** និង [redacted] **សីហា** ដល់ចំណុចកើតហេតុក៏បានជ្រុលទៅបុកម៉ូតូជនរងគ្រោះម៉ាកនិចមួយគ្រឿងពណ៌ស និងមួយគ្រឿងទៀតម៉ាកធូដេ ពណ៌ផ្កាឈូក បណ្តាលអោយឈ្មោះ [redacted] **ហេង** សន្លប់ពេលដឹងខ្លួនត្រូវសមត្ថកិច្ចសួរចំលើយចំណែកឯឈ្មោះ [redacted] **សីហា** និងឈ្មោះ **វិទ្ធ** បានរត់គេចខ្លួន ព្រោះខ្លាចប្រជាជននៅទីនោះវាយ។ ក្រោយមកឈ្មោះ **ប៉ាត់ សីហា** ចូលបំភ្លឺត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង ចំណែកឈ្មោះ **វិទ្ធ** បានរត់គេចខ្លួនបាត់ នេះគ្រាន់តែជាចំលើយដោះសារឈរកន្ទួចខ្លួនតែប៉ុណ្ណោះ ព្រោះតាមចំលើសដើមបណ្តឹងរដ្ឋប្បវេណីបានឆ្លើយបញ្ជាក់ថា នៅថ្ងៃកើតហេតុខ្លួន

កំពុងជិះម៉ូតូស្រាប់តែមានចោរឆក់កាបូបខ្លួនដួលសន្ធប់តែម្តង បណ្តាលអោយខ្លួនត្រូវរបួសបាក់ឆ្អឹងកាំបិតខាងស្តាំ ដាច់មុខ ដាច់ចិញ្ចឹម ដេកពេទ្យ កាលម៉ែត្រ ព្យាបាលចំនួន៥ថ្ងៃ។

-តាមចំលើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]**នីតា** ថា: ហេតុការណ៍កើតនៅ កាលពីថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២៨ ម៉ោងប្រហែល០៨ និង៣០នាទីឈប់ ខ្ញុំជិះម៉ូតូម៉ាកធូដេ ពណ៌ផ្កាឈូក មិនចាំស្លាកលេខ ជាម៉ូតូរបស់ខ្ញុំ ជិះចេញពីធ្វើការនៅម្តុំប៉ុលឌីញ ទៅតាមផ្លូវព្រះនរោត្តមមិនដឹងដល់ចំណុចណាទេ ស្រាប់តែមានចោរឆក់កាបូបខ្ញុំ ដួលម៉ូតូសន្ធប់តែម្តង មិនដឹងរឿងហេតុការណ៍អ្វីទៀតទេ ចោរឆក់កាបូបខ្ញុំមិនដឹងមានគ្នាប៉ុន្មាននាក់ទេ មិនស្គាល់មុខ និងមិនដឹងចោរឆក់នោះ ជិះម៉ូតូម៉ាកអ្វីដែរ។ ពេលខ្ញុំដួលម៉ូតូ បានទៅដេកពេទ្យកាល់ម៉ែត្រព្យាបាលរយៈពេល ៥ថ្ងៃ ខ្ញុំត្រូវរបួសបាក់ឆ្អឹងដងកាំបិតខាងស្តាំ ដាច់មុខផ្នែកខាងស្តាំ ដាច់ចិញ្ចើមខាងឆ្វេង ដេរចំនួន ០៨ថ្នេរ និងស្រាំឆ្អឹងក្នុងត្រចៀកខាងស្តាំ ដោយស្តាប់មិនលឺទេសព្វថ្ងៃនេះ ថ្នៃព្យាបាលខ្ញុំមិនដឹងអស់ប៉ុន្មានទេ ចាំខ្ញុំដាក់ភស្តុតាងឯកសារថ្នៃពេទ្យតាមក្រោយ ។ ករណីនេះមិនមែនជាករណីគ្រោះថ្នាក់ចរាចរណ៍ទេ គឺករណីឆក់កាបូប។

-តាមរបាយការណ៍សំយោគលេខ ០៧៧/២០១៨ រ.ប.ក ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៨ បានសន្និដ្ឋានថា: ឈ្មោះ [redacted]**ហេង** ភេទប្រុស អាយុ១៩ឆ្នាំ , ឈ្មោះ [redacted]**សីហា** ភេទប្រុស អាយុ២៥ឆ្នាំ (ឃាត់ខ្លួន) និងឈ្មោះ **រិទ្ធ** ភេទប្រុស អាយុប្រហែល២០ឆ្នាំ (គេចខ្លួន) ពិតជាបានប្រព្រឹត្តអំពើ លួចមានស្ថានទម្ងន់ទោសប្រើអំពើហិង្សា (ឆក់កាបូបស្តាយបណ្តាលអោយជនរងគ្រោះដួលរបួសធ្ងន់) កាលពីថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៨ វេលាម៉ោង ២១:00នាទី នៅចំណុចផ្លូវព្រះនរោត្តម កែងផ្លូវលេខ១៣៦ ភូមិទី១០ សង្កាត់ផ្សារកណ្តាលទី២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ប្រាកដមែន។

-តាមរបាយការណ៍សំយោគរបស់សមត្ថកិច្ចខណ្ឌដូនពេញ ចម្លើយរបស់ជនរងគ្រោះ ជាដើមបណ្តឹងរដ្ឋប្បវេណី និងវត្ថុតាងនានា គឺមានភាពស៊ីសង្វាក់គ្នាដែលអាចបញ្ជាក់បានថា: ជនជាប់ចោទឈ្មោះ [redacted]**ហេង** ភេទប្រុស អាយុ១៩ឆ្នាំ , ឈ្មោះ [redacted]**សីហា** ភេទប្រុស អាយុ២៥ឆ្នាំ ពិតជាបានប្រព្រឹត្តអំពើ លួចមានស្ថានទម្ងន់ទោសប្រាកដមែន។

-ចម្លើយបដិសេធរបស់ជនជាប់ចោទឈ្មោះ [redacted]**ហេង** និងឈ្មោះ [redacted]**សីហា** គឺគ្រាន់តែជាការដោះសារ ដើម្បីឲ្យរួចផុតពីការចោទប្រកាន់តែប៉ុណ្ណោះ ហើយក៏គ្មានភស្តុតាងណាមួយយកមកធ្វើជាសំអាងគួរឲ្យជឿជាក់បានឡើយ។

-ជនជាប់ចោទជានីតិជនមានកម្រិតអាយុត្រូវទទួលខុសត្រូវ នូវអំពើរបស់ខ្លួនដែលបានប្រព្រឹត្ត ព្រមទាំងយល់ដឹងអំពីផលវិបាកដែលកើតចេញពីអំពើរបស់ខ្លួន ដែលស្ថិតនៅក្នុងលក្ខខណ្ឌនៃការទទួលខុសត្រូវព្រហ្មទណ្ឌ។

-អំពើរបស់ជនជាប់ចោទធ្វើឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយសង្គមធ្ងន់ធ្ងរ ដែលអំពើនេះត្រូវបានកំណត់ថាជាបទល្មើស និងត្រូវផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣, ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

-មានភស្តុតាងបញ្ជាក់ពីពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted]ហេង ភេទប្រុស អាយុ១៩ឆ្នាំ និងឈ្មោះ [redacted]សីហា ភេទប្រុស អាយុ២៥ឆ្នាំ ពិបទ: លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើ

ភ្នំពេញ កាលថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៨ បទល្មើសដែលមានបញ្ញត្តិ និងឲ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ នៃក្រមព្រហ្មទណ្ឌ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] នីតា ទាមទារសំណងផ្នែកព្យាបាល ខាតពេលវេលាចំនួន ១២,០០០,០០០រៀល (ដប់ពីរលានរៀល) ពីជនជាប់ចោទ គប្បីតុលាការពិចារណា និងសម្រេចតាមភាពជាក់ស្តែង។

## <u>ហេតុផលនៃសេចក្តីសម្រេច</u>

១) ផ្តន្ទាទោសជនជាប់ចោទ

ក/ឈ្មោះ [redacted] ហេង ភេទប្រុស អាយុ១៩ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល៥ឆ្នាំ(ប្រាំឆ្នាំ)។

ខ/ឈ្មោះ [redacted] សីហា ភេទប្រុស អាយុ២៥ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធគារកំណត់រយៈពេល៥ឆ្នាំ(ប្រាំឆ្នាំ)។

**ពីបទ: លួចមានស្ថានទម្ងន់ទោស ដោយការប្រព្រឹត្តអំពើហិង្សា** ប្រព្រឹត្តនៅចំណុចផ្លូវព្រះនរោត្តម កែងផ្លូវលេខ១៣៦ ភូមិទី១០ សង្កាត់ផ្សារថ្មី២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៨ បទល្មើសដែលមានបញ្ញត្តិ និងឲ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

២) បង្គាប់ឲ្យជនជាប់ចោទឈ្មោះ [redacted] ហេង ភេទប្រុស អាយុ ១៩ឆ្នាំ និងឈ្មោះ [redacted] សីហា ភេទប្រុស អាយុ ២៥ឆ្នាំ សងផ្នែកព្យាបាលរបួស និងខាតពេលវេលាចំនួន ១០.០០០.០០៛ (ដប់លានរៀល) ឲ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] នីតា ការទាមទារលើសពីនេះបដិសេធចោល។

-សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ២០១៩ ចំពោះមុខជនជាប់ចោទ និងចំពោះមុខមេធាវីការពារជនជាប់ចោទ កំពាំងមុខដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈនៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៩ ។

-មានសិទ្ធិប្តឹងទាស់ និងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់កំណត់។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |
| [redacted] | | | |

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃអង្គារ ១៥កើត ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ ២០១៩

ក្រឡាបញ្ជី

[redacted]



Scanned with CamScanner